# ផលប៉ះពាល់នៃធ្យូងថ្មទៅលើសិទ្ធិមនុស្ស

ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

APHR

## T: តើហេតុអ្វីធ្យូងថ្មមិនល្អចំពោះអាកាសធាតុរបស់យើង?

ធ្យូងថ្មគឺជាប្រភពថាមពលដែលបញ្ចេញឧស្ម័នយ៉ាងច្រើន និងជាសារធាតុបញ្ចេញឧស្ម័នកាបូនឌីអុកស៊ីតច្រើនជាងគេបំផុតនៅក្នុងពិភពលោក ដែលជាហេតុបង្កឲ្យមានការប្រែប្រួលអាកាសធាតុ។ ធ្យូងថ្មបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រមាណ ៤១% នៃឧស្ម័នផ្ទះកញ្ចក់ទាំងអស់ទូទាំងពិភពលោក។ ដោយហេតុនេះហើយ ទើបអគ្គលេខាធិការអង្គការសហប្រជាជាតិបានជម្រុញឲ្យបណ្ដាមេដឹកនាំពិភពលោកនានា បញ្ឈប់ការប្រើប្រាស់ធ្យូងថ្មជាប្រភពថាមពលតទៅទៀត និងបញ្ឈប់ការសាងសង់រោងចក្រធ្យូងថ្មថ្មីបន្ថែមទៀត ក្រោយឆ្នាំ២០២០។ ផ្ទុយទៅវិញ បណ្ដាប្រទេសនានាត្រូវបានលើកទឹកចិត្តឲ្យប្ដូរមកប្រើប្រាស់ប្រភពថាមពលស្អាត និងកកើតឡើងវិញ ដូចជា ពន្លឺព្រះអាទិត្យ និងខ្យល់។

ប៉ុន្តែ មានតែតំបន់អាស៊ីអាគ្នេយ៍ប៉ុណ្ណោះ ដែលជាតំបន់មានការកើនឡើងនូវការផលិតថាមពលអគ្គិសនីដោយប្រើធ្យូងថ្ម។ គម្រោងពង្រីកថាមពលអគ្គិសនីធ្យូងថ្មនៅតំបន់អាស៊ីអាគ្នេយ៍ និងតំបន់អាស៊ីខាងត្បូង មានចំនួនស្មើនឹងពាក់កណ្ដាលនៃគម្រោងពង្រីកថាមពលអគ្គិសនីធ្យូងថ្មរបស់ពិភពលោក។ នៅពេលដែលមានការជម្រុញឲ្យប្ដូរមកប្រើប្រាស់ថាមពលកកើតឡើងវិញជំនួសឲ្យការប្រើប្រាស់ធ្យូងថ្ម តំបន់អាស៊ីអាគ្នេយ៍ត្រូវបានចាត់ទុកជាតំបន់ដែលមានការអនុវត្តខ្សោយជាងគេ ក្នុងចំណោមតំបន់នានាក្នុងពិភពលោក។

ការប្រើប្រាស់ធ្យូងថ្មក្នុងការផ្គត់ផ្គង់ថាមពលនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ឬ អាស៊ាន (ASEAN) គឺមិនសមស្របជាមួយនឹងការសន្យារបស់អាស៊ាន ក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ក្នុងការទប់កំណើនសីតុណ្ហភាពជាមធ្យមរបស់ពិភពលោកឲ្យស្ថិតនៅក្រោម ២អង្សាសេ លើកម្រិតសីតុណ្ហភាពនៅមុនពេលចាប់ផ្ដើមមានបដិវត្តន៍ឧស្សាហកម្ម និងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីកម្រិតកំណើនសីតុណ្ហភាព ឲ្យនៅត្រឹម ១,៥អង្សាសេ លើកម្រិតសីតុណ្ហភាពនៅមុនពេលចាប់ផ្ដើមមានបដិវត្តន៍ឧស្សាហកម្ម។

ខាងក្រោមនេះ គឺជារូបភាពបង្ហាញអំពីបច្ចុប្បន្នភាព និងគម្រោងនៃការផលិតថាមពលអគ្គិសនីដោយប្រើធ្យូងថ្ម នៅក្នុងអាស៊ាន ដោយប្រៀបធៀបជាមួយនឹងកម្រិតថាមពលដែលរដ្ឋសមាជិកអាស៊ានត្រូវសម្រេចឲ្យបានតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស។




នេះជាបញ្ហាដ៏លំបាកបំផុត ដោយសារតំបន់អាស៊ីអាគ្នេយ៍ស្ថិតនៅក្នុងចំណោមតំបន់ដែលងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុបំផុតរបស់ពិភពលោក ហើយជាតំបន់មានចំនួនប្រជាជនច្រើន និងកំពុងកើនឡើង ដែលងាយរងគ្រោះពីហានិភ័យអាកាសធាតុដ៏ធ្ងន់ធ្ងរ ដែលជាការគម្រាមកំហែងដល់សិទ្ធិមនុស្សជាមូលដ្ឋានបំផុតរបស់ប្រជាជនទាំងអស់ក្នុងតំបន់។

## តើហេតុអ្វីធ្យូងថ្មមិនល្អចំពោះខ្យល់?

ការផលិតថាមពលអគ្គិសនីដោយប្រើធ្យូងថ្មបង្កឲ្យមានការបំពុលខ្យល់ ដែលនាំឲ្យមានបញ្ហាជាច្រើនចំពោះសុខភាព និងនាំឲ្យអាយុខ្លី។ ការបញ្ចេញឧស្ម័នចេញពីរោងចក្រថាមពលអគ្គិសនីដុតធ្យូងថ្មនាពេលបច្ចុប្បន្ន បានបណ្តាលឲ្យបាត់បង់ជីវិតមនុស្សប្រមាណ ២០.០០០នាក់ ក្នុងមួយឆ្នាំ ហើយចំនួននេះត្រូវបានប៉ាន់ស្មានថានឹងកើនដល់ ៧០.០០០នាក់ នៅឆ្នាំ២០៣០ ប្រសិនបើរោងចក្រថាមពលអគ្គិសនីធ្យូងថ្មទាំងអស់ត្រូវបានសាងសង់តាមការគ្រោងទុក។

ការបំពុលខ្យល់ក៏នាំឲ្យមានការចំណាយផងដែរ។ សម្រាប់អាស៊ាន ការចំណាយខាងក្រៅដែលពាក់ព័ន្ធនឹងបញ្ហានេះ ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ១៦៧ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៤ ហើយត្រូវបានប៉ាន់ប្រមាណថានឹងកើន ៣៥% គឺជាមធ្យមប្រមាណជា ២២៥ ពាន់លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ នៅឆ្នាំ២០២៥។




*Climate Analytics, 2019, Decarbonising South and Southeast Asia, p.47, edited for readability.*

**ការប្តូរមកប្រើថាមពលកកើតឡើងវិញ នឹងជួយកាត់បន្ថយសារធាតុបំពុលតូចៗល្អិតក្នុងខ្យល់ ព្រមទាំងជួយដល់សុខភាព និងជួយកាត់បន្ថយការចំណាយផ្សេងៗដែលពាក់ព័ន្ធនឹងការបំពុលខ្យល់ ជាពិសេសកាត់បន្ថយការស្លាប់ដោយសារការបំពុលខ្យល់។**

## តើហេតុអ្វីធ្យូងថ្មមិនល្អចំពោះទឹក របស់យើង?

ធ្យូងថ្ម គឺជាទម្រង់មួយក្នុងចំណោមទម្រង់នៃការបង្កើតអគ្គិសនីដែលត្រូវការទឹកច្រើនបំផុត ដោយសារវាប្រើប្រាស់ និងបំពុលទឹកក្នុងបរិមាណដ៏ច្រើនសម្បើម។ ការប្រើប្រាស់ទឹកដោយរោងចក្រថាមពលអគ្គិសនីធ្យូងថ្មមួយ កម្លាំង ១.០០០ មេហ្គាវ៉ាត់ គឺស្មើនឹងបរិមាណទឹកដែលត្រូវបានប្រើប្រាស់ដោយមនុស្សកន្លះលាននាក់ ក្នុងមួយឆ្នាំ។ ការធ្វើឲ្យកខ្វក់ទឹកដោយសារធ្យូងថ្ម ក៏អាចបង្កឲ្យមានជំងឺធ្ងន់ធ្ងរជាច្រើនផងដែរ ដូចជា ជំងឺបេះដូង និងសរសៃឈាម ជំងឺមហារីកសួត និងស្បែក និងជំងឺបម្រែបម្រួលហ្សែន។

**ផ្ទុយទៅវិញ ការផលិតថាមពលអគ្គិសនីពីពន្លឺព្រះអាទិត្យ និងខ្យល់ នឹងជួយឲ្យការប្រើប្រាស់ទឹកស្ថិតក្នុងកម្រិតក្បែរសូន្យ។**

## តើហេតុអ្វីធ្យូងថ្មមិនល្អចំពោះដី របស់យើង?

ការដុតធ្យូងថ្មផលិតបានជាផេះធ្យូងថ្ម ដែលមានផ្ទុកនូវលោហធាតុធ្ងន់ (អាសេនីក សំណ បារត) ព្រមទាំងសារធាតុវិទ្យុសកម្ម។ ការដឹកជញ្ជូនផេះធ្យូងថ្ម នាំឲ្យមានការបំពុលប្រភពទឹក និងដី។ ដីដែលនៅខាងក្រោម និងជុំវិញទីធ្លាបោះចោលផេះធ្យូងថ្មត្រូវបានបំពុល ដោយសារសារធាតុពុលបានចូលទៅក្នុងខ្សែចង្វាក់នៃការចិញ្ចឹមជីវិតដោយស៊ីសាច់គ្នាជាអាហារ។ ការបំពុលដីក៏អាចបណ្តាលមកពីទឹកភ្លៀងអាស៊ីត ដែលបង្កដោយចំហេះធ្យូងថ្មផងដែរ។

**ខណៈពេលដែលថាមពលកកើតឡើងវិញក៏ត្រូវការទីកន្លែងដែលមានផ្ទៃដីធំ ដីនៅជុំវិញកង្ហារទាញថាមពលអគ្គិសនីដោយខ្យល់ ឬបន្ទះអគ្គិសនីស្រូបពន្លឺព្រះអាទិត្យ អាចប្រើប្រាស់សម្រាប់ការធ្វើកសិកម្ម និងមិនអាចត្រូវបានបំពុលនោះទេ។**

# តើអ្វីចាំបាច់ត្រូវកើតឡើង?

ដើម្បីកម្រិតការប្រែប្រួលអាកាសធាតុ និងដើម្បីកាត់បន្ថយផលប៉ះពាល់នៃធ្យូងថ្មចំពោះសិទ្ធិមនុស្ស ដូចជា សិទ្ធិសុខភាព លទ្ធភាពទទួលបានទឹក សិទ្ធិទទួលបានចំណីអាហារគ្រប់គ្រាន់ថ្លៃថ្នូរ និងបរិស្ថានមានផាសុកភាពជាដើម វាពិតជាមានសារៈសំខាន់ណាស់ដែលរដ្ឋសមាជិកអាស៊ានត្រូវបញ្ឈប់ជាបន្ទាន់នូវការប្រើប្រាស់ថាមពលដែលពឹងផ្អែកលើធ្យូងថ្ម និងជំនួសវិញត្រូវធានាឲ្យមានការកាត់បន្ថយតម្រូវការថាមពលក្នុងកម្រិតដ៏ច្រើន និងឲ្យមានការប្ដូរមកប្រើប្រភពថាមពលកកើតឡើងវិញ ដែលបញ្ចេញឧស្ម័នកម្រិតទាប។

## ដើម្បីធ្វើបែបនេះបាន រដ្ឋសមាជិកអាស៊ានត្រូវ៖

- ១. ធានាថា គ្មានការសាងសាង់រោងចក្រថាមពលអគ្គិសនីធ្យូងថ្មថ្មីបន្ថែមទៀតឡើយ ក្រោយឆ្នាំ២០២០។
- ២. ធានាថា រោងចក្រថាមពលអគ្គិសនីនឹងបញ្ឈប់ការប្រើប្រាស់ធ្យូងថ្មដើម្បីផលិតថាមពលអគ្គិសនី នៅឆ្នាំ២០៤០។

## ការណ៍នេះនឹងតម្រូវឲ្យប្រទេសជាសមាជិក ត្រូវ៖

- ១. បង្កើនឲ្យបានឆាប់រហ័សនូវការប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជា ថាមពលពីពន្លឺព្រះអាទិត្យ និងខ្យល់។
- ២. ធានាឲ្យមានការកាត់បន្ថយតម្រូវការថាមពលក្នុងចំនួនដ៏ច្រើន នៅក្នុងគ្រប់វិស័យទាំងអស់។

គោលនយោបាយនឹងចាំបាច់ត្រូវគិតគូរអំពីសិទ្ធិមនុស្ស និងយេនឌ័រ សិទ្ធិកម្មករ ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ការតស៊ូជម្នះភាពក្រីក្រ និងការបង្កើនលទ្ធភាពទទួលបានថាមពលដែលមានសុវត្ថិភាព និងតម្លៃសមរម្យ។

**ជំងឺ COVID-19៖ ផែនការតំបន់ក្នុងការស្តារសេដ្ឋកិច្ចពីវិបត្តិនៃជំងឺ COVID-19 គឺជាឱកាសតែមួយគត់ដែលជួយជម្រុញសន្ទុះនៃការផ្លាស់ប្តូរនេះ ដោយការគាំទ្រ និងលើកស្ទួយវិស័យថាមពលស្អាត និងកកើតឡើងវិញ។ តំបន់អាស៊ីអាគ្នេយ៍ គឺជាទីតាំងដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញ ដែលនឹងជួយកាត់បន្ថយបន្ទុកសេដ្ឋកិច្ចនៃការនាំចូល ហានិភ័យសុខភាព និងការចំណាយដែលកើតចេញពីការបំពុលខ្យល់។ វាក៏នឹងជួយស្តារសេដ្ឋកិច្ច តាមរយៈឱកាសនៃការបង្កើតការងារផងដែរ ដោយសារតំបន់អាស៊ីអាចបង្កើតការងារចំនួន ៦៣% នៃការងារសរុប ក្នុងវិស័យប្រភពថាមពលកកើតឡើងវិញ។**

## ប្រទេសឥណ្ឌូនេស៊ី

ប្រទេសឥណ្ឌូនេស៊ី គឺជាប្រទេសផលិតធ្យូងថ្មធំជាងគេបំផុតទី៥ ក្នុងពិភពលោក។ ជិត ៦០% នៃការផ្គត់ផ្គង់អគ្គិសនីនៃប្រទេសនេះ គឺបានមកពីសមត្ថភាពថាមពលធ្យូងថ្មរបស់ខ្លួន។ គោលនយោបាយថាមពលជាតិ ឆ្នាំ២០១៤ របស់ប្រទេសឥណ្ឌូនេស៊ី បានព្យាករណ៍ថា នឹងមានការកើនឡើងបីដងនូវការប្រើប្រាស់ធ្យូងថ្មក្នុងស្រុក នៅឆ្នាំ២០៥០ ហើយប្រទេសនេះ គឺជាប្រទេសមួយក្នុងចំណោមប្រទេសចំនួនប្រាំក្នុងពិភពលោក ដែលបានសាងសង់រោងចក្រធ្យូងថ្មថ្មីបន្ថែមទៀត ក្នុងឆ្នាំ២០២០។

**ជំងឺ COVID-19៖ កម្មវិធីស្តារជាតិ មិនបានផ្តល់នូវវិធានការដើម្បីឆ្ពោះទៅរកសេដ្ឋកិច្ចប្រកបដោយចីរភាពនោះទេ។ ផ្ទុយទៅវិញ កម្មវិធីនេះជួយដល់ក្រុមហ៊ុនឧស្សាហកម្មថាមពលអគ្គិសនីដើរដោយធ្យូងថ្មក្នុងចំនួនដ៏ច្រើន ដោយគ្មានលក្ខខណ្ឌ។ ក៏ប៉ុន្តែជាមធ្យម ការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញអាចបង្កើតការងារផ្ទាល់នៅក្នុងប្រទេស រហូតដល់ទៅ ២៩០.០០០ ការងារ នៅចន្លោះឆ្នាំ២០២០ និងឆ្នាំ២០៣០។**

### អនុសាសន៍

- កាត់បន្ថយសមត្ថភាពថាមពលពីធ្យូងថ្ម ដែលត្រូវបានបង្កើតឡើងនាពេលបច្ចុប្បន្ន ចំនួន ១០% នៅមុនឆ្នាំ២០៣០ និងបញ្ឈប់ការប្រើប្រាស់ធ្យូងថ្ម នៅឆ្នាំ២០៤០។
- លុបបំបាត់នូវឧបត្ថម្ភធនឥន្ធនៈផូស៊ីល និងឧបសគ្គចំពោះការវិនិយោគលើថាមពលកកើតឡើងវិញ។
- បង្កើនការវិនិយោគលើប្រភពថាមពលកកើតឡើងវិញ ដើម្បីអាចផ្គត់ផ្គង់ថាមពលចំនួន ៥០% នៃការផ្គត់ផ្គង់ថាមពលរបស់ប្រទេសឥណ្ឌូនេស៊ី នៅឆ្នាំ២០៣០ និង ១០០% នៅឆ្នាំ២០៥០។
- កំណត់លក្ខខណ្ឌឲ្យមានការកាត់បន្ថយឧស្ម័នកាបូនឌីអុកស៊ីត ស្របតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ចំពោះក្រុមហ៊ុនឧស្សាហកម្មអគ្គិសនី ដូចជា ក្រុមហ៊ុន Perusahaan Listrik Negara (PLN) នៅក្នុងវិធានការជួយស្តារសេដ្ឋកិច្ចក្រុមហ៊ុនដែលរងផលប៉ះពាល់ពីជំងឺCOVID-19។

## ប្រទេសម៉ាឡេស៊ី

១/៥ (មួយភាគប្រាំ) នៃថាមពលរបស់ប្រទេសម៉ាឡេស៊ី ត្រូវបានបង្កើតឡើងពីរោងចក្រដុតធ្យូងថ្ម។ ថាមពលកកើតឡើងវិញនៅតែអាចបង្កើតបានតែ ២% នៃសមាសភាពថាមពលសរុបរបស់ប្រទេសនេះ និងមានការយឺតយ៉ាវសម្រាប់ការផ្លាស់ប្តូរដើម្បីកាត់បន្ថយឲ្យតិចជាងមុននូវថាមពលដែលត្រូវការកាបូនដ៏ច្រើន។

**ជំងឺ COVID-19៖ ក្នុងចំណោមកញ្ចប់ថវិកាលើកទឹកចិត្តចំនួនបួនរបស់ប្រទេសម៉ាឡេស៊ី មានតែគម្រោងទិដ្ឋភាពបៃតងប៉ុណ្ណោះ ដែលមានតម្លៃដល់ទៅ ១៣ ពាន់លានរីងហ្គីត (៣ ពាន់លានដុល្លារអាមេរិក) ក្នុងចំណោមគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីអភិវឌ្ឍឲ្យមានអំពូលភ្លើងបំភ្លឺផ្លូវប្រភេទអិលអ៊ីឌី បន្ទះអគ្គិសនីស្រូបពន្លឺព្រះអាទិត្យដាក់លើដំបូលផ្ទះ និងអ្វីៗផ្សេងទៀត។ ក្រសួងថាមពល (MESTECC) ក៏នឹងបើកការដេញថ្លៃសម្រាប់គម្រោងផលិតថាមពលអគ្គីសនីពីពន្លឺព្រះអាទិត្យ កម្លាំង ១.៤០០ មេហ្គាវ៉ាត់ ផងដែរ។**

### អនុសាសន៍

- ដាក់ចេញនូវវិធានការដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញ និងការស្តារប្រព័ន្ធបៃតង នៅក្នុងកញ្ចប់ថវិកាស្តារសេដ្ឋកិច្ចពីជំងឺ COVID-19។
- ធានាថា ប្រទេសម៉ាឡេស៊ីបញ្ឈប់ការប្រើប្រាស់ធ្យូងថ្ម នៅឆ្នាំ២០៤០។
- ពង្រឹងការអភិវឌ្ឍន៍ទីផ្សារថាមពលដើរដោយខ្យល់ និងពន្លឺព្រះអាទិត្យ ជាពិសេសតាមរយៈការដោះស្រាយបញ្ហាដែលដាក់កំហិតលើសមត្ថភាពផលិតថាមពលនេះ។

## ប្រទេសមីយ៉ាន់ម៉ា

ទោះបីជាមានការពឹងផ្អែកតិចតួចលើធ្យូងថ្មដើម្បីផលិតថាមពល ប្រទេសមីយ៉ាន់ម៉ាមិនបានប្ដេជ្ញាចិត្តក្នុងការបញ្ឈប់គម្រោងសាងសង់រោងចក្រថាមពលអគ្គិសនីធ្យូងថ្មថ្មីបន្ថែមនោះទេ។ គោលដៅនាពេលបច្ចុប្បន្នសម្រាប់ការផលិតថាមពលដើរដោយខ្យល់ និងពន្លឺព្រះអាទិត្យ មានកម្រិតទាបនៅឡើយ គឺដាក់គោលដៅត្រឹមតែ ១២% នៅឆ្នាំ២០២៥ និងសមត្ថភាពថាមពលពីពន្លឺព្រះអាទិត្យ មានកម្លាំងត្រឹមតែ ១៧០ មេហ្គាវ៉ាត់ប៉ុណ្ណោះ។

**ជំងឺ COVID-19៖ កញ្ចប់ថវិកាលើកទឹកចិត្តដ៏ធំត្រូវបានប្រកាសកាលពីខែមីនា ឆ្នាំ២០២០ ដែលរួមបញ្ចូលទាំង ការជម្រុញឲ្យមានបន្ទះអគ្គិសនីស្រូបពន្លឺព្រះអាទិត្យដាក់លើដំបូលផ្ទះ និងកិច្ចសន្យាដេញថ្លៃសមត្ថភាពថាមពលពីពន្លឺព្រះអាទិត្យ កម្លាំង ១ ជីហ្គាវ៉ាត់។**

### អនុសាសន៍

- កែលម្អក្របខណ្ឌគតិយុត្តិសម្រាប់ថាមពលកកើតឡើងវិញ ជាពិសេស ដោយការបង្កើតកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនីស្តង់ដាសាធារណៈ និងតម្លាភាព ការលើកទឹកចិត្តពន្ធ កម្មវិធីរដ្ឋាភិបាល និងផែនការសាធារណៈ។
- បង្កើនគោលដៅសម្រាប់ការផលិតថាមពលកកើតឡើងវិញឆ្នាំ២០៣០ ឲ្យបាន ៥០%។
- ដាក់បញ្ចូលបន្ថែមនូវវិធានការដើម្បីជម្រុញការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញ និងការស្តារប្រព័ន្ធបៃតង នៅក្នុងវិធានការស្តារសេដ្ឋកិច្ចពីជំងឺ COVID-19។
- បញ្ឈប់ទាំងស្រុងនូវការប្រើប្រាស់ធ្យូងថ្ម នៅឆ្នាំ២០៤០។

## ប្រទេសហ្វីលីពីន

ប្រទេសហ្វីលីពីន គឺជាប្រទេសដំបូងគេក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលបានសម្រេចផ្អាកឲ្យប្រើប្រាស់ ធ្យូងថ្មថ្មី និងដែលបានគាំទ្រដល់ប្រភពថាមពលកកើតឡើងវិញ។ ទោះជាយ៉ាងណា ការផ្អាកនេះមិនត្រូវបានដាក់បញ្ចូលនៅក្នុង "ផែនការថាមពលប្រទេសហ្វីលីពីន" នោះទេ ដែលផែនការនេះបានស្នើឲ្យពង្រីកបន្ថែមនូវចំណែកធ្យូងថ្មនៅក្នុងប្រភពថាមពលចម្រុះ ពីកម្រិតដែលខ្ពស់ស្រាប់ចំនួន ៥២,១% នៅក្នុងឆ្នាំ២០១៨ ទៅដល់ ៥៥,៣% នៅឆ្នាំ២០៤០។

**ជំងឺ COVID-19៖ ផែនការសង្គ្រោះសេដ្ឋកិច្ច រួមបញ្ចូលនូវវិធានការមួយចំនួនក្នុងការស្តារប្រព័ន្ធបៃតង ដែលក្នុងនោះក៏មានច្បាប់ស្តីពីការស្តារក្រុមហ៊ុនសាជីវកម្ម និងការលើកទឹកចិត្តពន្ធសម្រាប់សហគ្រាស ដោយកាត់បន្ថយពន្ធចំពោះក្រុមហ៊ុនដែលពាក់ព័ន្ធនឹងថាមពលកកើតឡើងវិញ។**

### អនុសាសន៍

- ធានាថា ការពិនិត្យឡើងវិញនូវផែនការថាមពលប្រទេសហ្វីលីពីន និងរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ ចំពោះកិច្ចព្រមព្រៀងទីក្រុងប៉ារីស បានដាក់បញ្ចូលនូវការផ្អាកឲ្យប្រើប្រាស់ធ្យូងថ្ម។
- ដាក់ចេញគោលដៅច្បាស់លាស់ក្នុងការបញ្ឈប់ការប្រើប្រាស់ធ្យូងថ្ម ដើម្បីផ្គត់ផ្គង់ថាមពល នៅឆ្នាំ២០៤០
- បញ្ជាក់អំពី និងអនុវត្តឲ្យបានពេញលេញនូវការផ្អាកឲ្យប្រើប្រាស់ធ្យូងថ្ម នៅក្នុងគោលនយោបាយនានា។
- ដាក់បញ្ចូលបន្ថែមនូវវិធានការដើម្បីជម្រុញការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញ និងការស្តារប្រព័ន្ធបៃតង នៅក្នុងវិធានការស្តារសេដ្ឋកិច្ចពីជំងឺ COVID-19។

## ប្រទេសថៃ

ផែនការអភិវឌ្ឍថាមពលអគ្គិសនីប្រទេសថៃ មានគោលបំណងធ្វើឲ្យគម្រោងថាមពលកកើតឡើងវិញ អាចមានសមត្ថភាពដល់ទៅ ៣៧% នៃសមត្ថភាពថាមពលអគ្គិសនីថ្មី នៅឆ្នាំ២០៣៧ ខណៈពេលដែលសមត្ថភាពថាមពលអគ្គិសនីពីការដុតធ្យូងថ្មនឹងត្រូវរក្សាឲ្យនៅកម្រិតត្រឹម ១២% ដែលជាកម្រិតមិនសមស្របតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

**ជំងឺ COVID-19៖ បច្ចុប្បន្ននេះ <u>មិនឃើញមានការផ្ដួចផ្ដើមនូវគម្រោងបៃតង</u> នៅក្នុងកញ្ចប់ថវិកាចំនួនបួនរបស់ប្រទេសថៃ សម្រាប់ការស្ដារសេដ្ឋកិច្ចពីជំងឺ COVID-19 នោះទេ។**

### អនុសាសន៍

- ប្រទេសថៃត្រូវតែកែលម្អសមត្ថភាពបណ្ដាញខ្សែអគ្គិសនី និងក្របខណ្ឌគតិយុត្តិរបស់ខ្លួន ដើម្បីជួយដល់ការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញបន្ថែមទៀត។
- ដាក់បញ្ចូលនូវវិធានការនានាដើម្បីជម្រុញការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញ និងការស្ដារប្រព័ន្ធបៃតង នៅក្នុងវិធានការស្ដារសេដ្ឋកិច្ចពីជំងឺ COVID-19។
- ធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍថាមពលអគ្គិសនី និងគោលនយោបាយពាក់ព័ន្ធដទៃផ្សេងទៀត ដើម្បីធានាថាប្រទេសថៃឈប់ប្រើប្រាស់ធ្យូងថ្ម នៅឆ្នាំ២០៤០។

## ប្រទេសវៀតណាម

សេចក្ដីព្រាងផែនការអភិវឌ្ឍថាមពលអគ្គិសនី ៨ បញ្ជាក់ថា គម្រោងបង្កើតសមត្ថភាពថាមពលពីធ្យូងថ្មមួយចំនួនត្រូវបានលុបចោល ឬផ្អាក ក៏ប៉ុន្តែប្រទេសវៀតណាមនៅតែមានគម្រោងក្នុងការអភិវឌ្ឍថាមពលពីធ្យូងថ្ម ដែលមានកម្លាំង ១៨ ជីហ្គាវ៉ាត់ នៅឆ្នាំ២០២០-២០២៥ និងបង្កើតបំពង់បង្ហូរធ្យូងថ្មធំជាងគេទី២ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

**ជំងឺ COVID-19៖ សមត្ថភាពថាមពលពីពន្លឺព្រះអាទិត្យបានកើនឡើង។ ទោះជាយ៉ាងណាប្រទេសវៀតណាមមិនបានលើកឡើងអំពីថាមពលកកើតឡើងវិញ និងការស្ដារប្រព័ន្ធបៃតង នៅក្នុងកញ្ចប់ថវិកាលើកទឹកចិត្តដើម្បីស្ដារសេដ្ឋកិច្ចរបស់ខ្លួននោះទេ។**

### អនុសាសន៍

- បោះបង់ផែនការក្នុងការផលិតថាមពលអគ្គិសនីពីការដុតធ្យូងថ្មថ្មី ជាពិសេសនៅក្នុងផែនការអភិវឌ្ឍថាមពលអគ្គិសនី ៨។
- បញ្ឈប់ទាំងស្រុងនូវការប្រើប្រាស់ធ្យូងថ្ម នៅឆ្នាំ២០៤០។
- កែលម្អមហិច្ចតានៃគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់សកម្មភាពថាមពល នៅក្នុងរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិ និងសេចក្ដីសម្រេច ៥៥។
- ដាក់បញ្ចូលនូវវិធានការនានាដើម្បីជម្រុញការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញ និងការស្ដារប្រព័ន្ធបៃតង នៅក្នុងវិធានការស្ដារសេដ្ឋកិច្ចពីជំងឺ COVID-19។

# តើសមាជិកសភាអាចធ្វើអ្វីខ្លះ?

- ជម្រុញឲ្យរដ្ឋាភិបាលរបស់ខ្លួន ប្តេជ្ញាចិត្តក្នុងការបញ្ឈប់ការប្រើប្រាស់ធ្យូងថ្ម នៅឆ្នាំ២០៤០ និងបញ្ឈប់ការសាងសង់រោងចក្រថាមពលអគ្គិសនីធ្យូងថ្មថ្មី នៅឆ្នាំ២០២០ ស្របតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ដោយការដាក់សំណួរទៅកាន់ក្រសួងពាក់ព័ន្ធនានានៅក្នុងសភា។

- ជម្រុញឲ្យមានការដាក់ចេញនូវគោលដៅទាំងនេះនៅក្នុងច្បាប់ថាមពល ព្រមទាំងនៅពេលអនុម័តថវិកាជាតិ។

- តស៊ូមតិដើម្បីឲ្យមណ្ឌលបោះឆ្នោតរបស់អ្នក គ្មានធ្យូងថ្ម។ ស្វែងយល់ថាតើមានរោងចក្រថាមពលអគ្គិសនីធ្យូងថ្មនៅក្នុងមណ្ឌលបោះឆ្នោតរបស់អ្នកដែរឬទេ? និងថាតើមានសក្តានុពលដែលមិនទាន់យកមកប្រើប្រាស់ សម្រាប់ការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញនៅទីនោះដែរឬទេ? ពិភាក្សាជាមួយអ្នកបោះឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោតរបស់អ្នក អំពីការបង្កើតគម្រោងថាមពលកកើតឡើងវិញ ដើម្បីដឹងថាតើពួកគេគិតថា ពួកគេនឹងទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះឬទេ និងដើម្បីដឹងថាតើក្តីបារម្ភរបស់ពួកគេមានអ្វីខ្លះ?

- ចុះហត្ថលេខាលើសេចក្តីប្រកាសរបស់ក្រុមសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស (APHR) និងប្តេជ្ញាចិត្តក្នុងការប្រើប្រាស់មុខងាររបស់ខ្លួន ដើម្បីតស៊ូមតិឲ្យមានការស្តារសេដ្ឋកិច្ចពីជំងឺ COVID-19 ប្រកបដោយចីរភាព ត្រឹមត្រូវ និងគ្មានធ្យូងថ្ម។ ឧទាហរណ៍ ការធានាថា វិធានការស្តារសេដ្ឋកិច្ចមិនធ្វើឲ្យចុះខ្សោយប្រសិទ្ធភាពនៃវិធានការការពារបរិស្ថានជាធរមានឡើយ ដោយត្រូវរួមបញ្ចូលនូវការគាំទ្រដោយផ្ទាល់ និងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដល់ប្រព័ន្ធថាមពលកកើតឡើងវិញ និងការបន្ធូរបន្ថយលក្ខខណ្ឌចំពោះអង្គភាពវិស័យឯកជន ដែលកាត់បន្ថយឧស្ម័នកាបូនឌីអុកស៊ីត ស្របតាមគោលបំណងនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

- ធានាថា គណៈកម្មការសភាដែលអ្នកជាសមាជិកបានយកបញ្ហានៃការប្រែប្រួលអាកាសធាតុ និងបញ្ហាធ្យូងថ្ម ធ្វើជាបញ្ហាចម្បងជាផ្លូវការ និងបានធ្វើការជាមួយអ្នកជំនាញអាកាសធាតុ អង្គការសង្គមស៊ីវិល និងអ្នកដទៃផ្សេងទៀត។ នៅក្នុងប្រទេសមួយចំនួន គណៈកម្មការជំនាញអាចស្នើសុំ និងដាក់សំណួរដល់រដ្ឋាភិបាល អំពីការអនុវត្តរបស់រដ្ឋាភិបាលដើម្បីសម្រេចគោលបំណងនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងអាចស្នើសុំការឆ្លើយតបជាផ្លូវការ។

## សម្រាប់ព័ត៌មានបន្ថែម

- សេចក្តីប្រកាស និងសិក្ខាសាលាតាមប្រព័ន្ធអនឡាញជាបន្តបន្ទាប់របស់ក្រុមសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស (APHR) ស្តីពីវិធានការនានាដែលសមាជិកសភាអាស៊ានអាចអនុវត្ត ដើម្បីជម្រុញឲ្យមានការស្តារសេដ្ឋកិច្ចពីជំងឺ
- វិទ្យាស្ថានវិភាគអាកាសធាតុ, ខែមិថុនា ឆ្នាំ២០១៩, របាយការណ៍ស្តីពីការកាត់បន្ថយឧស្ម័នកាបូនឌីអុកស៊ីត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងតំបន់អាស៊ីខាងត្បូង។
- បណ្តាញអង្គការសន្តិភាពបៃតង, ខែកញ្ញា ឆ្នាំ២០២០, សន្ទស្សន៍ពិន្ទុនៃវិស័យថាមពលអគ្គិសនីនៅតំបន់អាស៊ីអាគ្នេយ៍, ការវាយតម្លៃវឌ្ឍនភាពនៃថាមពលជាតិ, ការផ្លាស់ប្តូរប្រឆាំងនឹងវិថីឆ្ពោះទៅរកសីតុណ្ហភាព ១,៥ អង្សា។
- ក្រុមហ៊ុនសាជីវកម្មសេវាហិរញ្ញវត្ថុ និងធនាគារ ហូឡង់អន្តរជាតិ, ខែសីហា ឆ្នាំ២០២០, របាយការណ៍ស្តីពីចំណាត់ការបៃតងមិនត្រឹមត្រូវនៃតំបន់អាស៊ី ក្នុងការឆ្លើយតបនឹងជំងឺ COVID-19។

ប្រសិនបើលោកអ្នកចាប់អារម្មណ៍ចង់ទទួលបានព័ត៌មានបន្ថែម ឬចង់ចូលរួមដោះស្រាយបញ្ហាទាំងនេះ នៅក្នុងប្រទេស និងសភា របស់លោកអ្នក សូមទំនាក់ទំនងលោកស្រី *Cannelle Gueguen-Teil* តាមរយៈអ៊ីម៉ែល *cannelle@aseanmp.org*

ASEAN PARLIAMENTARIANS FOR HUMAN RIGHTS
www.aseanmp.org | twitter / facebook / instagram: @aseanmp
DECEMBER 2020

FRIEDRICH EBERT STIFTUNG